# ស្វែងយល់អំពីជម្រើស បោះឆ្នោតរបស់អ្នក



**LAVOTE.GOV មានអ្វីគ្រប់យ៉ាងដែលអ្នកត្រូវការ សម្រាប់ការបោះឆ្នោតបឋមថ្ងៃទី ៧ ខែមិថុនា។** The LA County Registrar-Recorder/County Clerk គឺជាប្រភពផ្លូវការសម្រាប់ព័ត៌មានការបោះឆ្នោត និងធនធានបោះឆ្នោតត្រឹមត្រូវ និងមិនលំអៀង។ ការបោះឆ្នោតមិនដែលងាយស្រួល, ស្រណុកជាងមុន និងមានសុវត្ថិភាពជាងនេះទេ។ អានអំពីរបៀប នៃការរៀបចំសម្រាប់ការបោះឆ្នោត!

## តើខ្ញុំអាចចុះឈ្មោះបោះឆ្នោត ដោយរបៀបណា? តើថ្ងៃណា ជាកាលបរិច្ឆេទផុតកំណត់នៃការចុះឈ្មោះ?

ប្រសិនបើអ្នកបានផ្លាស់ទីលំនៅ, ជាអ្នកថ្មីនៅក្នុងខោនធី LA County, ឬបោះឆ្នោតជាលើកដំបូង, អ្នក **ត្រូវតែ** ចុះ ឈ្មោះបោះឆ្នោត អោយបានមុន **ថ្ងៃទី ២៣ខែឧសភា ឆ្នាំ ២០២២** ដើម្បីទទួលបានសន្លឹកឆ្នោតបោះឆ្នោតតាមសំបុត្រ។ មធ្យោបាយងាយស្រួលបំផុតក្នុងការចុះឈ្មោះបោះឆ្នោត គឺចូលទៅកាន់ LAVOTE.GOV.

មានប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោតជាក្រដាសដាក់នៅតាមអគាររដ្ឋាភិបាលភាគច្រើន – ដូចជាបណ្ណាល័យ ឬការិយាល័យ DMV ជាដើម ប្រសិនបើអ្នកមិនមានអ៊ីនធឺណិតប្រើប្រាស់នោះទេ។

## តើខ្ញុំអាចតាមដានសន្លឹតឆ្នោតដែលបោះតាមសំបុត្ររបស់ខ្ញុំ បានទេ?

បាទ/ចាស! អ្នកអាចតាមដានសន្លឹកឆ្នោតរបស់អ្នកគ្រប់ជំហ៊ានទាំងអស់ ដោយការជាវលើ ***សន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?*** (california.ballottrax.net) ដោយឥតគិតថ្លៃ។ អ្នកនឹងទទួលបានការជូនដំណឹងតាមរយៈសារជាអក្សរ, អ៊ីម៉ែល, ឬសារជាសំឡេង អំពីស្ថានភាពសន្លឹកឆ្នោតដែលបានផ្ញើតាមប្រៃសណីយ៍របស់អ្នក។ បន្ទាប់ពីអ្នកប្រគល់នូវសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ ផងដែរអ្នកក៏នឹងទទួលបាននូវការជូនដំណឹងមួយ ស្តីអំពីថាតើពេលណា សន្លឹកឆ្នោតនោះនឹងត្រូវទទួលបាននៅការិយាល័យចុះឈ្មោះ ហើយថាតើពេលណា គោរប់វា។

## តើជម្រើសបោះឆ្នោតរបស់ខ្ញុំ មានអ្វីខ្លះ?

1. **បោះឆ្នោតតាមសំបុត្រ។** នឹងមានការផ្ញើសំបុត្រសម្រាប់ការបោះឆ្នោតបឋមខែមិថុនា ទៅកាន់អ្នកបោះឆ្នោត ទាំងអស់ដែលបានចុះឈ្មោះនៅក្នុង ខោនធី LA County។ សន្លឹកឆ្នោតនឹងចាប់ផ្តើមផ្ញើនៅថ្ងៃទី៥ ខែឧសភា។ អ្វីដែលអ្នកត្រូវធ្វើ គឺបំពេញវា, ចុះហត្ថលេខាលើស្រោមសំបុត្រដែលដាក់អោយផ្ញើមកវិញ ហើយផ្ញើវាត្រឡប់មកវិញ។ កុំរង់ចាំ។ បោះឆ្នោតជាមុន!

2. **ទម្លាក់នៅប្រអប់ទម្លាក់សន្លឹកឆ្នោត។** អ្នកអាចជៀសផុតពីការតម្រង់ជួរនៅមណ្ឌលបោះឆ្នោតដោយបោះ ឆ្នោតជាមុន និងបញ្ជូនសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញនៅទីតាំងមួយក្នុងចំណោមទីតាំងផ្លូវការចំនួន៤00 នៃប្រអប់ទម្លាក់សន្លឹកឆ្នោត។ បញ្ជីទីតាំងងាយស្រួលនៅជិតអ្នកត្រូវបានបញ្ចូលនៅក្នុងកញ្ចប់បោះ ឆ្នោតតាមសំបុត្រ។

3. **ទៅកាន់មណ្ឌលបោះឆ្នោតណាមួយ ដែលចាប់ផ្តើមពីថ្ងៃទី ២៨ ខែឧសភា។** ប្រសិនបើអ្នកបោះឆ្នោតដោយផ្ទាល់, វានឹងចំណេញនូវពេលវេលា ដោយការប្រើប្រាស់នូវលិខិតមណ្ឌលបោះឆ្នោត (Poll Pass) ចល័ត! វាគឺជាមធ្យោបាយងាយស្រួលមួយ ក្នុងការសន្សំសំចៃពេលវេលានៅមណ្ឌលបោះឆ្នោត ដោយធ្វើការជ្រើសរើសជាមុន មុនពេលអ្នកចាកចេញពីផ្ទះរបស់អ្នក។ នឹងមានការផ្ញើសំបុត្រដាច់ដោយឡែកមួយ ទៅកាន់ អ្នកដែលបានចុះឈ្មោះបោះឆ្នោតទាំងអស់ ដែលបង្ហាញពីទីតាំងនៃមណ្ឌលបោះឆ្នោតដែលនៅជិតអ្នកបំផុត។

បញ្ជីពេញលេញនៃប្រអប់ទម្លាក់សន្លឹកឆ្នោតនិងទីតាំងមណ្ឌលបោះឆ្នោត នឹងមាននៅ LAVOTE.GOV.

**ការបោះឆ្នោតមិនដែលងាយស្រួលជាងនេះទេ នៅក្នុងខានធី LA COUNTY។**

ចូលទៅកាន់ **LAVOTE.GOV** ដើម្បីស្វែងយល់បន្ថែម

Official information